## ខ្លឹមសារសង្ខេបសាលដីកាសាលាឧទ្ធរណ៍លេខ២៨(២០១៤)

**ពាក្យគន្លឹះ**

គោលការណ៍នីត្យានុកូលភាព, ប្ដូរប្រភេទបទល្មើស (អំពើអនាចារ), អនីតិជន, ស្ថានសម្រាល, ទោសសម្រាប់ជនបរទេស

### ១. នីតិវិធីនិងសេចក្ដីសម្រេច

ជនជាប់ចោទ ត្រូវបានចោទថាបានប្រព្រឹត្តអំពើអនាចារក្នុងខែមេសា ឆ្នាំ២០០៧ លើកុមារីអាយុ១៤ឆ្នាំនៅទីក្រុងភ្នំពេញ បានចាត់ជាបទល្មើសបំពានមាត្រា៨នៃច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់ ឆ្នាំ២០០៨។ សាលាដំបូងរាជធានីភ្នំពេញ ផ្ដន្ទាទោសតាមសាលក្រមលេខ២២(២០០៨) ដាក់ទោស១៥ឆ្នាំក្នុងពន្ធនាគារ និងសងជំងឺចិត្ត៧០០០ដុល្លា ដល់ជនរងគ្រោះ (បណ្ដេញចេញក្រោយពីអនុវត្តទោសស្ថាពរចប់)។ សាលាឧទ្ធរណ៍ តម្កល់សាលក្រមនេះ (សាលដីកាលេខ៥៩ឆ្នាំ២០១១)។ ជនជាប់ចោទបន្តប្ដឹងទៅតុលាការកំពូល ដែលចេញសាលដីកាលេខ១៥៤ ឆ្នាំ២០១៣ តម្កល់សាលដីកាលេខ៥៩ លើកលែងចំណុចដាក់ទោស។ សាលាឧទ្ធរណ៍ជំនុំជម្រះឡើងវិញ និងបានចេញ<u>សាលដីកាលេខ២៨(២០១៤)</u>នេះ ដោយបានសម្រេចដាក់ទោសតែ៧ឆ្នាំ(បទទិញពេស្យាចារកុមារតាមមាត្រា៣៤.២នៃច្បាប់ដដែល)។

**២.** *មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាព...ទិញពេស្យាចារកុមារ...អាយុតិចជាង១៥ឆ្នាំ។* ***៥...*** *ផ្ដន្ទាទោស..ត្រឹមកម្រិតអប្បបរមា ដោយសារថា អំពើ....មិនមានលក្ខណៈធ្ងន់ធ្ងរពេក...បានសារភាពកំហុស... មិនលំបាកដល់នីតិវិធី...មេធាវីការពារ...ជនរងគ្រោះក៏មិនបានជំទាស់ដែរ...។*

### ២. កំណត់សំគាល់

**ក.** ចាប់តាំងពីឆ្នាំកើតហេតុ មកដល់ថ្ងៃសវនាការ ជនជាប់ចោទជាប់ពន្ធនាគារចំនួន៧ឆ្នាំ ហើយនីតិវិធីមានរយៈពេល៧ឆ្នាំផងដែរមកដល់ឆ្នាំ២០១៤។ ការកាត់សេចក្ដីលើកទី២ គឺអនុលោមតាមការចង្អុលបង្ហាញរបស់តុលាការកំពូល ចំណុចផ្សេងពីនេះ បានចូលជាស្ថាពរទៅហើយ។

**ខ.** សាលាឧទ្ធរណ៍ បានយោងដល់ក្រមព្រហ្មទណ្ឌឆ្នាំ២០១០ មាត្រា១០(ទោសស្រាលត្រូវយកមកអនុវត្ត)៖ *ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬធ្ងន់ជាង បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម ។ ប៉ុន្តែការផ្តន្ទាទោសដែលជាស្ថាពរហើយនោះត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។* ក្នុងសំណុំរឿងនេះ បទល្មើសត្រូវបានប្ដូរពី អំពើអនាចារ មកជាការទិញ

ពេស្យាចារកុមារ (អាចអង្គហេតុដូចគ្នា) និងបានដាក់ទោស៧ឆ្នាំវិញ ដែលជាទោសអប្បបរមានៃបទទិញពេស្យាចារកុមារ (មាត្រា៣៤)។ <u>នៅមានមន្ទិលចំពោះការយោងដល់មាត្រា១០នៃក្រមព្រហ្មទណ្ឌ</u> ដោយសារមាត្រា១០ សំដៅលើការអនុវត្តទោសស្រាល (តាមច្បាប់ថ្មី) លើបទល្មើសដដែល (ជាប្រយោជន៍ដល់ជនជាប់ចោទ) ដែលទោសតាមច្បាប់ចាស់សម្រាប់បទល្មើសដដែលនេះ ធ្ងន់ជាង ត្រូវបានប្រកាសដោយចៅក្រម និងនៅមិនទាន់ស្ថាពរនៅឡើយ។ **គ.** ជនរងគ្រោះអាយុក្រោម១៥ឆ្នាំមិនរារាំងដល់ការដាក់ទោសអប្បបរមាទេ។